# មជ្ឈមណ្ឌលឯកសារកម្ពុជា

## គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

### ការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»
### ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

ចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងខែមករាឆ្នាំ១៩៧៩មក កិច្ចខិតខំប្រឹងប្រែងក្នុងការបង្រៀនប្រវត្តិសាស្ត្រនៃរបបនេះដល់ប្រជាជនកម្ពុជា ជាពិសេសក្មេងជំនាន់ក្រោយ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រជាច្រើន រួមទាំងការបង្រៀននៅសាលាដែលមានលក្ខណៈជាការឃោសនានយោបាយដើម្បីទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ និងការនិយាយប្រាប់រឿងរ៉ាវដ៏ជូរចត់នេះពីសំណាក់ឪពុកម្តាយទៅកូនចៅរបស់ខ្លួន ។ តាមរយៈមធ្យោបាយបែបនេះ ការបង្រៀនប្រវត្តិសាស្ត្រត្រូវបានមើលឃើញថា មិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងមិនអាចឋិតថេរបានយូរអង្វែងឡើយ ។

២៨ឆ្នាំក្រោយមក សៀវភៅសិក្សា«*ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)*»ថ្មីមួយ ត្រូវបានបោះពុម្ពជាលើកដំបូងក្នុងឆ្នាំ២០០៧ ។ សៀវភៅនេះ ត្រូវបានសរសេរឡើងដោយលោក ឌី ខាំបូលី អ្នកស្រាវជ្រាវខ្មែរមួយរូបដែលកំពុងបម្រើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានជំនួយទ្រទ្រង់ហិរញ្ញវត្ថុពីសំណាក់អង្គការទុនជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងវិទ្យាស្ថានសង្គមសេរី ។ លោក ឌី ខាំបូលី បានចំណាយពេលវេលាចំនួន៣ឆ្នាំ ដើម្បីសរសេរនិងបោះពុម្ពផ្សាយសៀវភៅនេះ ។ សៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានត្រួតពិនិត្យ ដោយគណៈកម្មការត្រួតពិនិត្យរបស់ក្រសួង ហើយចុងបញ្ចប់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សានៅទូទាំងប្រទេសកម្ពុជា ។ រហូតមកដល់ថ្ងៃនេះ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួន៣០០.០០០ក្បាល ត្រូវបានចែកជូនដល់សិស្សានុសិស្សនៅទូទាំងប្រទេសកម្ពុជាដោយឥតគិតថ្លៃ ។

ក្នុងឆ្នាំ២០០៩ ក្រោមការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅណែនាំគ្រូបង្រៀន សម្រាប់លោកគ្រូអ្នកគ្រូប្រើប្រាស់ក្នុងការបង្រៀនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅនេះ ត្រូវបានរៀបចំឡើងយ៉ាងសិរិតសំរាំងសម្រាប់គ្រូប្រវត្តិសាស្ត្រ និងមានគោលបំណងឲ្យលោកគ្រូអ្នកគ្រូមានលទ្ធភាពក្នុងការបង្រៀនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឲ្យសមស្របតាមក្បួនខ្នាត និងគរុកោសល្យត្រឹមត្រូវ ។ លើសពីនេះទៀត សៀវភៅលំហាត់របស់សិស្សគឺកំពុងតែត្រូវបានបញ្ចប់ មុនពេលដែលសៀវភៅនេះត្រូវ

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

បញ្ជូនទៅបោះពុម្ព ដើម្បីជាជំនួយដល់សិស្សឲ្យមានការយល់ដឹងកាន់តែច្បាស់លាស់ទៅលើសៀវភៅប្រវត្តិសាស្ត្រ ។

ចាប់ពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមជំនួយទ្រទ្រង់ពីប្រទេសប៊ែលហ្ស៊ិក ប្រទេសស៊ុយអែត ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក វិទ្យាស្ថានសង្គមសេរី ប្រទេសដាណឺម៉ាក និងប្រទេសម្ចាស់ជំនួយមួយចំនួនទៀត បានបើកសិក្ខាសាលាមួយ ដើម្បីបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិចំនួន២៤រូបមកពីក្រសួងអប់រំ យុវជន និងកីឡា និង១៥រូបមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លើវិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងលើប្រធានបទផ្សេងៗដែលជាប់ពាក់ព័ន្ធដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅបណ្តាប្រទេសដទៃៗទៀត និងច្បាប់អន្តរជាតិ ។អ្នកជំនាញជាតិនិងអន្តរជាតិ ត្រូវបានអញ្ជើញឲ្យមកចូលរួម និងជួយរៀបចំសិក្ខាសានេះ ។ នៅចុងឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយគ្រូបង្គោលថ្នាក់ជាតិចំនួន៣៩រូប បានរៀបចំវគ្គបណ្តុះបណ្តាលលើកទី២ ដែលធ្វើឲ្យគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨០រូប បានទទួលការបណ្តុះបណ្តាលនេះដោយជោគជ័យ ។

ជាលទ្ធផលសម្រាប់វគ្គបណ្តុះបណ្តាលលើកទី២ សិក្ខាសាលាស្តីពីការបង្កើនសមត្ថភាពឲ្យកាន់តែប្រសើរឡើង ត្រូវបានប្រារព្ធធ្វើឡើងរយៈពេល៣ថ្ងៃនៅខេត្តសៀមរាប ។ គ្រូបង្គោលថ្នាក់ជាតិចំនួន ១២ រូប និងគ្រូឧទ្ទេសថ្នាក់ខេត្តចំនួន ១៨០ រូប បានចូលរួមក្នុងវគ្គសិក្ខាសាលានេះ ដើម្បីទទួលបានព័ត៌មាននិងចំណេះដឹងច្រើនបន្ថែមទៀតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មុនពេលចុះទៅបង្រៀនដល់គ្រូប្រវត្តិសាស្ត្រនៅមូលដ្ឋានចំនួន១.៦២៧នាក់ ។

វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកដំបូង បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១១ ខែមេសា នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រិត្យការខេត្ត ដែលរួមមាន ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ប្រកបដោយជោគជ័យ ។ ជាក់ស្តែង វគ្គបណ្តុះបណ្តាលនេះ បានចូលរួមដោយលោកគ្រូអ្នកគ្រូមកពីខេត្តកំពត ៦៨នាក់, កែប ៨នាក់, ព្រះសីហនុ ២៨នាក់, កោះកុង ១៧នាក់, ក្រចេះ ៣០នាក់, មណ្ឌលគិរី ៤នាក់, រតនគិរី ៥នាក់, ព្រះវិហារ ១៨នាក់, និងស្ទឹងត្រែង ១៥នាក់ ។

វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី២ នឹងប្រព្រឹត្តទៅចាប់ពី **ថ្ងៃទី៨ ដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១០** នៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រិត្យការខេត្តចំនួន ៣ គឺ ខេត្តតាកែវ ព្រៃវែង និងកំពង់ធំ ដែលនឹងចូលរួមដោយលោកគ្រូអ្នកគ្រូប្រវត្តិវិទ្យាសរុបចំនួន ៣៤៨នាក់ ដែលក្នុងនោះរួមមាន ១៥០នាក់ មកពីខេត្តតាកែវ, ១០០នាក់ មកពីខេត្តព្រៃវែង, និង ៧៧នាក់ មកពីខេត្តកំពង់ធំ ដោយបូកបញ្ចូលជាមួយលោកគ្រូអ្នកគ្រូចំនួន ២១នាក់ទៀត មកពីខេត្តឧត្តរមានជ័យ ។

# កម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកទី ២
# ពីថ្ងៃទី៨ ដល់ទី១៤ ខែឧសភា ឆ្នាំ២០១០

*ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១០៖ ចេញដំណើរឆ្ពោះទៅកាន់ មជ្ឈមណ្ឌលបណ្តុះបណ្តា និងវិក្រិត្យការខេត្ត*
*ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០៖ រសៀល ឬយប់ ជួបពិភាក្សាជាមួយគ្រូបង្គោលថ្នាក់ជាតិ និងខេត្ត*

## *វគ្គបណ្តុះបណ្តាលថ្ងៃទី១៖ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១០*

០៧:៣០-០៨:០០ ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក

០៨:០០-០៩:០០ **ពិធីបើកវគ្គនៅក្នុងខេត្ត** និង សេចក្តីណែនាំទូទៅសម្រាប់វគ្គបណ្តុះបណ្តាល
- ពន្យល់អំពីសារៈសំខាន់ នៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងគោលបំណងនៃវគ្គបណ្តុះបណ្តាល ។
- ពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ

០៩:០០-១០:០០ បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ **ជំពូក ១** សំណួរនិងចម្លើយរបស់សិក្ខាកាម

១០:០០-១០:១៥ សម្រាករយៈពេលខ្លី

១០:១៥-១២:០០ បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ **ជំពូក ២** សំណួរនិងចម្លើយរបស់សិក្ខាកាម

១២:០០-០១:៣០ សម្រាកសម្រាប់អាហារថ្ងៃត្រង់

០១:៣០-០៣:០០ គ្រូបណ្តុះបណ្តាលឡើងបង្រៀនជាគំរូនៅក្នុងជំពូក១ និងពិភាក្សាលើមេរៀននៅក្នុងជំពូក១នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៣:០០-០៣:១៥ សម្រាករយៈពេលខ្លី

០៣:១៥-០៤:៣០ គ្រូបណ្តុះបណ្តាលឡើងបង្រៀនជាគំរូនៅក្នុងជំពូក២ និងពិភាក្សាលើមេរៀននៅក្នុងជំពូក២នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៤:៣០-០៥:០០ សរុប និង វាយតម្លៃប្រចាំថ្ងៃ ។

**សកម្មភាពមុនការបង្រៀន**

មេរៀនទី១ : សេចក្តីផ្តើមនៃមេរៀន

មេរៀនទី២ ៖ ស្វែងយល់អំពីចំណេះដឹងដំបូងរបស់សិស្ស

**ជំពូក១ ៖ សេចក្តីសង្ខេប**

មេរៀនទី១ ៖ អំណានជំពូក១

**ជំពូក២ ៖ តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?**

មេរៀនទី១ ៖ អំណានជំពូក២

មេរៀនទី២ ៖ តើ ប៉ុល ពត ជានរណា?

អ្នកបណ្តុះបណ្តាលពិភាក្សាសកម្មភាពមុនការបង្រៀន ជំពូក១ និងជំពូក២ នៅក្នុងក្រុមធំ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

## វគ្គបណ្តុះបណ្តាលថ្ងៃទី២៖ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១០

០៧៖៣០-០៨៖០០ ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក

០៨៖០០-០៨៖១៥ សេចក្តីណែនាំក្នុងការបង្រៀន និងពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ

០៨៖១៥-០៨៖៤៥ បញ្ចាំងខ្សែភាពយន្ត ៖ *គុកទួលស្លែង គុកនៅភ្នំបាសិតនិងគុកនៅព្រៃវែងក្នុងឆ្នាំ ១៩៧៩ និងតំបន់រំដោះនៅកំពង់ចាមឆ្នាំ១៩៧៣ ។*

០៨៖៤៥-១០៖០០ បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
**ជំពូក៣** និង **ជំពូក៤** សំណួរនិងចម្លើយរបស់សិក្ខាកាម

១០៖០០-១០៖១៥ សម្រាករយៈពេលខ្លី

១០៖១៥-១២៖០០ គ្រូបណ្តុះបណ្តាលឡើងបង្រៀនមេរៀនគំរូ ពីជំពូក៣និងជំពូក៤នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។
សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើវិធីសាស្ត្របង្រៀននៅក្នុងជំពូក៣និងជំពូក៤នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

១២៖០០-០១៖៣០ សម្រាកសម្រាប់អាហារថ្ងៃត្រង់

០១៖៣០-០៣៖០០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៣ និងពិភាក្សាទៅលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក៣នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៣៖០០-០៣៖១៥ សម្រាករយៈពេលខ្លី

០៣:១៥-០៤:៣០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៤ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក៤ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៤:៣០-០៥:០០ សរុប និង វាយតម្លៃប្រចាំថ្ងៃ

**ជំពូក៣ : ការឡើងកាន់អំណាចរបស់ខ្មែរក្រហម**

មេរៀនទី១ : អំណានជំពូក៣

មេរៀនទី២ : រូបភាពថ្ងៃ១៧ មេសា ១៩៧៥

**ជំពូក៤ : ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ**

មេរៀនទី១ : អំណានជំពូក៤

មេរៀនទី២ : ពិនិត្យមើលក្រុមមេដឹកនាំខ្មែរក្រហម

អ្នកបណ្តុះបណ្តាលពិភាក្សាជំពូក៣និងជំពូក៤ នៅក្នុងក្រុមធំដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សិក្ខាកាមនៅក្នុងក្រុមតូចៗ៣នាក់ ឡើងធ្វើមេរៀនគំរូចំនួន៣ផ្សេងៗគ្នា ។ រយៈពេលនៃការឡើងធ្វើមេរៀនគំរូគឺ៣០នាទីសម្រាប់សិក្ខាកាមម្នាក់ ។ ការកំណត់ចំនួនសិក្ខាកាមសម្រាប់ឡើងធ្វើមេរៀនគំរូនឹងធ្វើឡើងទៅតាមចំនួនសិក្ខាកាមជាក់ស្តែងក្នុងខេត្តនីមួយៗ ។

## វគ្គបណ្តុះបណ្តាលថ្ងៃទី៣: ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០

០៧:៣០-០៨:០០ ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក

០៨:០០-០៨:៣០ សេចក្តីណែនាំក្នុងការបង្រៀន និងពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ ។

០៨:៣០-១០:០០ បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
**ជំពូក៥** និង **ជំពូក៦** សំណួរនិងចម្លើយរបស់សិក្ខាកាម

១០:០០-១០:១៥ សម្រាករយៈពេលខ្លី

១០:១៥-១២:០០ គ្រូបណ្តុះបណ្តាលឡើងបង្រៀនមេរៀនគំរូ ពីជំពូក៥និងជំពូក៦នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។
សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើវិធីសាស្ត្របង្រៀននៅក្នុងជំពូក៥និងជំពូក៦នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

១២:០០-០១:៣០ សម្រាកសម្រាប់អាហារថ្ងៃត្រង់

០១:៣០-០៣:០០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៥ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក៥ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៣:០០-០៣:១៥ សម្រាករយៈពេលខ្លី

០៣:១៥-០៤:៣០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៦ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក៦ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៤:៣០-០៥:០០ សរុប និង វាយតម្លៃប្រចាំថ្ងៃ

**ជំពូក៥ : ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ**

មេរៀនទី១ : អំណានជំពូក៥

មេរៀនទី២ : ការសម្ភែសន៍ "អំពីជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម"

**ជំពូក៦ : គម្រោងផែនការ៤ឆ្នាំ (១៩៧៧-១៩៨០)**

មេរៀនទី១ : អំណានជំពូក៦

មេរៀនទី២ : ប្រអប់សង្គ្រោះជីវិត

មេរៀនទី៣ : កាលបរិច្ឆេទ : ការវិភាគ និងការវាយតម្លៃនៅក្នុងក្រុម

មេរៀនទី៤ : ការវិភាគទៅលើមនោគមន៍វិជ្ជារបស់ខ្មែរក្រហម

អ្នកបណ្តុះបណ្តាលពិភាក្សាជំពូក៥ និងជំពូក៦ នៅក្នុងក្រុមធំដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សិក្ខាកាមនៅក្នុងក្រុមតូចៗ៣នាក់ ឡើងធ្វើមេរៀនគំរូចំនួន៣ផ្សេងៗគ្នា ។ រយៈពេលនៃការឡើងធ្វើមេរៀនគំរូគឺ៣០នាទីសម្រាប់សិក្ខាកាមម្នាក់ ។ ការកំណត់ចំនួនសិក្ខាកាមសម្រាប់ឡើងធ្វើមេរៀនគំរូនឹងធ្វើឡើងទៅតាមចំនួនសិក្ខាកាមជាក់ស្តែងក្នុងខេត្តនីមួយៗ ។

## វគ្គបណ្តុះបណ្តាលថ្ងៃទី៤: ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០

០៧:៣០-០៨:០០ ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក

០៨:០០-០៨:១៥ សេចក្តីណែនាំក្នុងការបង្រៀន និងពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ

០៨:១៥-០៨:៤៥ វាគ្មិន : អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បង្ហាញពីបទពិសោធន៍របស់ខ្លួននៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

០៨ៈ៤៥-១០ៈ០០ បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ
**ជំពូក៧** និង **ជំពូក៨** សំណួរនិងចម្លើយរបស់សិក្ខាកាម

១០ៈ០០-១០ៈ១៥ សម្រាករយៈពេលខ្លី

១០ៈ១៥-១២ៈ០០ គ្រូបណ្តុះបណ្តាលឡើងបង្រៀនមេរៀនគំរូ ពីជំពូក៧និងជំពូក៨នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។
សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើវិធីសាស្រ្តបង្រៀននៅក្នុងជំពូក៧និងជំពូក៨នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

១២ៈ០០-០១ៈ៣០ សម្រាកសម្រាប់អាហារថ្ងៃត្រង់

០១ៈ៣០-០៣ៈ០០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៧ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្រ្តបង្រៀននៅក្នុងជំពូក៧ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៣ៈ០០-០៣ៈ១៥ សម្រាករយៈពេលខ្លី

០៣ៈ១៥-០៤ៈ៣០ សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៨ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្រ្តបង្រៀននៅក្នុងជំពូក៨ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៤ៈ៣០-០៥ៈ០០ សរុប និង វាយតម្លៃប្រចាំថ្ងៃ

**ជំពូក៧ ៈ ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**

មេរៀនទី១ ៈ អំណានជំពូក៧

មេរៀនទី២ ៈ កំណត់ហេតុអំពីជីវិតរបស់ខ្ញុំក្រោមរបបខ្មែរក្រហម

មេរៀនទី៣ ៈ បទសម្ភាសន៍ ៈ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតម្នាក់

**ជំពូក៨ ៈ ប្រពន្ធ័សន្តិសុខ**

មេរៀនទី១ ៈ អំណានជំពូក៨

មេរៀនទី២ ៈ ភ្ញៀវធ្វើបទបឋកថា

អ្នកបណ្តុះបណ្តាលពិភាក្សាជំពូក៧និងជំពូក៨ នៅក្នុងក្រុមធំដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ។

សិក្ខាកាមនៅក្នុងក្រុមតូចៗ៣នាក់ ឡើងធ្វើមេរៀនគំរូចំនួន៣ផ្សេងៗគ្នា ។ រយៈពេលនៃការឡើងធ្វើមេរៀនគំរូគឺ៣០នាទីសម្រាប់សិក្ខាកាមម្នាក់ ។ ការកំណត់ចំនួនសិក្ខាកាមសម្រាប់ឡើងធ្វើមេរៀនគំរូនឹងធ្វើឡើងទៅតាមចំនួនសិក្ខាកាមជាក់ស្តែងក្នុងខេត្តនីមួយៗ ។

## វគ្គបណ្ដុះបណ្ដាលថ្ងៃទី៥៖ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០

| | |
|---|---|
| ០៧៖៣០-០៨៖០០ | ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក |
| ០៨៖០០-០៨៖១៥ | សេចក្ដីណែនាំក្នុងការបង្រៀន និងពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ ។ |
| ០៨៖១៥-០៨៖៤៥ | ខ្សែភាពយន្ត «នៅកៀនជញ្ជាំងនៃមន្ទីរសរ-២១» ។ |
| ០៨៖៤៥-១០៖០០ | បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ **ជំពូក៩** និង **ជំពូក១០** សំណួរនិងចម្លើយរបស់សិក្ខាកាម |
| ១០៖០០-១០៖១៥ | សម្រាករយៈពេលខ្លី |
| ១០៖១៥-១២៖០០ | គ្រូបណ្ដុះបណ្ដាលឡើងបង្រៀនមេរៀនគំរូ ពីជំពូក៩និងជំពូក១០នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។<br>សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើវិធីសាស្ត្របង្រៀននៅក្នុងជំពូក៩និងជំពូក១០នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ១២៖០០-០១៖៣០ | សម្រាកសម្រាប់អាហារថ្ងៃត្រង់ |
| ០១៖៣០-០៣៖០០ | សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក៩ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក៩ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ០៣៖០០-០៣៖១៥ | សម្រាករយៈពេលខ្លី |
| ០៣៖១៥-០៤៖៣០ | សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក១០ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក១០ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ០៤៖៣០-០៥៖០០ | សរុប និង វាយតម្លៃប្រចាំថ្ងៃ |

**ជំពូក៩ ៖ មន្ទីរស-២១ (គុកទួលស្លែង)**

មេរៀនទី១ ៖ អំណានជំពូក៩

មេរៀនទី២ ៖ នៅកៀនជញ្ជាំងនៃមន្ទីរស-២១

**ជំពូក១០ ៖ ទំនាក់ទំនងការបរទេស**

មេរៀនទី១ ៖ អំណានជំពូក១០

មេរៀនទី២ ៖ បណ្ណសីអំពីទំនាក់ទំនងការបរទេស

| |
|---|
| អ្នកបណ្តុះបណ្តាលពិភាក្សាជំពូក៩និងជំពូក១០នៅក្នុងក្រុមធំ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។<br>សិក្ខាកាមនៅក្នុងក្រុមតូចៗ៣នាក់ ឡើងធ្វើមេរៀនគំរូចំនួន៣ផ្សេងៗគ្នា ។ រយៈពេលនៃការឡើងធ្វើមេរៀនគំរូគឺ៣០នាទីសម្រាប់សិក្ខាកាមម្នាក់ ។ ការកំណត់ចំនួនសិក្ខាកាមសម្រាប់ឡើងធ្វើមេរៀនគំរូនឹងធ្វើឡើងទៅតាមចំនួនសិក្ខាកាមជាក់ស្តែងក្នុងខេត្តនីមួយៗ ។ |

## វគ្គបណ្តុះបណ្តាលថ្ងៃទី៦៖ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១០

| | |
|---|---|
| ០៧៖៣០-០៨៖០០ | ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក |
| ០៨៖០០-០៨៖៣០ | សេចក្តីណែនាំក្នុងការបង្រៀន និងពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ ។ |
| ០៨៖៣០-៩៖០០ | ការបញ្ចាំងខ្សែភាពយន្ត "កុមារកម្ពុជា" |
| ៩៖០០-១០៖០០ | បទបង្ហាញអំពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ **ជំពូក១១** និង **សេចក្តីបញ្ចប់** សំណួរនិងចម្លើយរបស់សិក្ខាកាម |
| ១០៖០០-១០៖១៥ | សម្រាករយៈពេលខ្លី |
| ១០៖១៥-១២៖០០ | គ្រូបណ្តុះបណ្តាលឡើងបង្រៀនមេរៀនគំរូ ពីជំពូក១១និងសេចក្តីបញ្ចប់នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។<br>សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើវិធីសាស្ត្របង្រៀននៅក្នុងជំពូក១១ និងសេចក្តីបញ្ចប់ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ១២៖០០-០១៖៣០ | សម្រាកសម្រាប់អាហារថ្ងៃត្រង់ |
| ០១៖៣០-០៣៖០០ | សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីជំពូក១១ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀននៅក្នុងជំពូក១១ នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ០៣៖០០-០៣៖១៥ | សម្រាករយៈពេលខ្លី |
| ០៣៖១៥-០៤៖៣០ | សិក្ខាកាមបំបែកជាក្រុមតូចៗ ឡើងបង្រៀនមេរៀនគំរូពីសេចក្តីបញ្ចប់ និងពិភាក្សាលើខ្លឹមសារនៃវិធីសាស្ត្របង្រៀន នៅក្នុងសេចក្តីបញ្ចប់នៃសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។ |
| ០៤៖៣០-០៥៖០០ | សរុប និង វាយតម្លៃប្រចាំថ្ងៃ |

**ជំពូក១១ ៖ ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ**

មេរៀនទី១ ៖ អំណានជំពូក១១

មេរៀនទី២ ៖ រូបភាពថ្ងៃរំដោះ

មេរៀនទី៣ ៖ ការធ្វើឲ្យប្រសើរឡើងនូវរបបអាហារ និងជីវជាតិសម្រាប់អ្នកដែលនៅរស់រានមានជីវិត ។

មេរៀនទី៤ ៖ ការសិក្សាប្រៀបធៀបអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ-លំហាត់ប្រៀបធៀប

មេរៀនទី៥ ៖ ខ្សែភាពយន្ត«កុមារកម្ពុជា»

**សេចក្តីបញ្ចប់ ៖ ផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន**

មេរៀនទី១ ៖ អំណានសេចក្តីបញ្ចប់

មេរៀនទី២ ៖ កំណាព្យដើម្បីរំឭកគុណដល់ព្រលឹងជាតិខ្មែរ

មេរៀនទី៣ ៖ តារាង K-W-L

មេរៀនទី៤ ៖ ការធ្វើឲ្យមានការផ្លាស់ប្តូរនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ

អ្នកបណ្តុះបណ្តាលពិភាក្សាជំពូក១១និងសេចក្តីបញ្ចប់នៅក្នុងក្រុមធំ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សិក្ខាកាមនៅក្នុងក្រុមតូចៗ៣នាក់ ឡើងធ្វើមេរៀនគំរូចំនួន៣ផ្សេងៗគ្នា ។ រយៈពេលនៃការឡើងធ្វើមេរៀនគំរូគឺ៣០នាទីសម្រាប់សិក្ខាកាមម្នាក់ ។ ការកំណត់ចំនួនសិក្ខាកាមសម្រាប់ឡើងធ្វើមេរៀនគំរូនឹងធ្វើឡើងទៅតាមចំនួនសិក្ខាកាមជាក់ស្តែងក្នុងខេត្តនីមួយៗ ។

## វគ្គបណ្តុះបណ្តាលថ្ងៃទី៧៖ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១០

០៨៖០០-០៨៖៣០ ចុះបញ្ជីវត្តមាន និងអាហារពេលព្រឹក

០៨៖៣០-០៩៖០០ ពិនិត្យមើលវត្ថុបំណងសម្រាប់ថ្ងៃនេះ ។

០៩៖០០-១០៖១៥ សំណួរនិងចម្លើយរបស់សិក្ខាកាម ទៅលើខ្លឹមសារទាំងមូលនៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

១០៖១៥-១០៖៣០ សម្រាករយៈពេលខ្លី

១០៖៣០-១២៖០០ គ្រូបណ្តុះបណ្តាលធ្វើបទបង្ហាញទៅលើសកម្មភាពសិក្សាបន្ថែម នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

១២៖០០-០១៖៣០ សម្រាកសម្រាប់អាហារថ្ងៃត្រង់

០១:៣០-០៣:០០ សំណួរនិងចម្លើយរបស់សិក្ខាកាម លើខ្លឹមសារនៃវិធីសាស្ត្រទាំងអស់នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ។

០៣:០០-០៣:៣០ សម្រាករយៈពេលខ្លី

០៣:៣០-០៤:៣០ ពិភាក្សាទៅលើការគ្រប់គ្រងគុណភាព, សរុប និង វាយតម្លៃប្រចាំថ្ងៃ

**(ប្រសិនបើមានពេលវេលាគ្រប់គ្រាន់ សូមបញ្ចាំងល្ខោននិយាយរឿង**
**«ទម្លាយភាពស្ងប់ស្ងាត់» ជូនដល់សិក្ខាកាមទស្សនាតែម្តង)**

| |
|---|
| **សកម្មភាពសិក្សាបន្ថែម** |
| ក) សកម្មភាពបឋម |
| ខ) ល្ខោននិយាយ «រឿងរ៉ាវរបស់ជនរងគ្រោះ ឬអតីតកម្មាភិបាលខ្មែរក្រហម» |
| គ) គម្រោងនៃការសិក្សាអំពីការប្រៀបធៀបអំពើប្រល័យពូជសាសន៍ |
| ឃ) សក្ខភាព ៖ កំណាព្យ |
| ង) គម្រោងស្រាវជ្រាវ ៖ បង្កើតតារាង W |
| ច) បង្កើតតារាង L៖ សកម្មភាពក្រោយគម្រោងស្រាវជ្រាវ |
| ឆ) ដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាដបឹងជើងឯក ។ |
| អ្នកបណ្តុះបណ្តាលពិភាក្សាលើសកម្មភាពបន្ថែមនៅក្នុងក្រុមធំ ដោយប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្រៀន សៀវភៅលំហាត់សម្រាប់សិស្ស និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ |
| ពិភាក្សាលើការគ្រប់គ្រងគុណភាព និងបំពេញតារាងវាយតម្លៃសម្រាប់វគ្គបណ្តុះបណ្តាលទាំងមូល ។ |

## ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១០៖ ចេញដំណើរត្រឡប់មកវិញ

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ផេង ពង្សរ៉ាស៊ី
ទូរស័ព្ទលេខ ០១៦ ២១២ ៨៨៨
អ៊ីម៉ែល truthrasy.p@dccam.org